**ស្ថានទូតអូស្ត្រាលី**

**រាជធានីភ្នំពេញ**

# សេចក្តីប្រកាសព័ត៌មាន

# អូស្ត្រាលីឆ្លើយតបទៅនឹងវិបត្តិទឹកជំនន់នៅកម្ពុជា

អូស្ត្រាលីនឹងផ្តល់ជំនួយសង្គ្រោះជីវិត ដល់គ្រួសារដែលបានប៉ះពាល់ដោយគ្រោះមហន្តរាយ ទឹកជំនន់នាពេលបច្ចុប្បន្ន នៅប្រទេសកម្ពុជា ។

រដ្ឋមន្ត្រីការបរទេស លោក **ខេវីន រ៉ាត់** (Kevin Rudd) បានថ្លែងក្នុងថ្ងៃនេះថា ទឹកប្រាក់ដែលមានចំនួនរហូតដល់២លានដុល្លារអូស្ត្រាលី នឹងត្រូវបានផ្តល់ដើម្បីឆ្លើយតបទៅនឹងវិបត្តិទឹកជំនន់ដ៏ធ្ងន់ធ្ងរនៅក្នុងប្រទេសកម្ពុជា ។ កញ្ចប់ថវិការផ្តល់ការគាំទ្រដល់ប្រជាជនដែលរងគ្រោះដោយទឹកជំនន់ រួមមាន ម្ហូបអាហារ ទឹក និងទីជម្រក ។ កញ្ចប់ថវិការក៏បានរាប់បញ្ចូលផងដែរនូវការគាំទ្រសំរាប់តម្រូវការស្បៀងក្នុងរយៈពេលយូរ ដែលអាចកើតមានដោយសារការប៉ះពាល់នៃទឹកជំនន់ទៅលើផលដំណាំស្រូវ ។

លោកជំទាវ **ផេននី រីឆាដស៍** (Penny Richards) ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជាបានមានប្រសាសន៍ថា “វិសាលភាពនៃទឹកជំនន់ដែលបណ្តាលមកពីខ្យល់ព្យុះត្រូពិចជាបន្តបន្ទាប់នៅក្នុងតំបន់ទន្លេមេគង្គនៃអាស៊ីអាគ្នេយ៍ បានប៉ះពាល់និងបំផ្លាញពាសពេញផ្ទៃប្រទេសកម្ពុជា ។”

“វាជាការក្រៀមក្រំបំផុត ដោយមានប្រជាជនយ៉ាងហោចណាស់ចំនួន២៤៧នាក់ ដែលបានស្លាប់ និងមានប្រជាជនចំនួនជាង១លាននាក់នៅក្នុងខេត្តចំនួន១៧នៃប្រទេសកម្ពុជាបានប៉ះពាល់ដោយទឹកជំនន់ ។ យើងសូមសំដែងនិងចូលរួមនូវមរណទុក្ខដ៏ក្រៀមក្រំ ចំពោះក្រុមគ្រួសារដែលបានបាត់បង់អ្នកជាទីស្រឡាញ់។”

“បណ្តាញគមនាគមន៍ ស្រែចំការ និងផលដំណាំត្រូវបានខូចខាតជាដំណំ ។ ទឹកជំនន់ដែលកំពុងកើតមាននៅក្នុងតំបន់ជាច្រើនបានបន្តបង្ករអោយប្រជាជនឃ្លាតឆ្ងាយពីផ្ទះសម្បែង និងកំពុងបំផ្លាញនូវជីវភាពរស់នៅរបស់ពួកគេ ។”

“ជាមួយគ្នានេះដែរ ក៏មានហានិយភ័យនៃជំងឺរាតត្បាតផងដែរ ដែលបណ្តាលមកពីការផ្គត់ផ្គង់ទឹកកខ្វក់និងប្រព័ន្ធអនាម័យដែលបានខូចខាត ។”

16B National Assembly Street, Sangkat Tonle Bassac Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

ការគាំទ្ររបស់អូស្ត្រាលីនឹងត្រូវបានផ្តល់តាមរយៈ អង្គការក្រៅរដ្ឋាភិបាលអូស្ត្រាលី ជាដៃគូរដែលមានប្រវត្តិស្នាដៃក្នុងការងារឆ្លើយតបទៅនឹងគ្រោះមហន្តរាយ និងសេវាកម្មស្តារឡើងវិញនៅក្នុងតំបន់ដែលប៉ះពាល់ខ្លាំង និងជួយដល់ប្រជាជនដែលងាយរងគ្រោះបំផុត ។

ជាក់ស្តែង ការផ្តល់ជំនួយរបស់ប្រទេសអូស្ត្រាលីរួមមាន ទឹកប្រាក់១លានដុល្លារអូស្ត្រាលីតាមរយៈ អង្គការក្រៅរដ្ឋាភិបាលអូស្ត្រាលី និងសហព័ន្ធអន្តរជាតិនៃសមាគមកាកបាទក្រហម សំរាប់គាំទ្រដល់កាកបាទក្រហមកម្ពុជាក្នុងការផ្តល់ស្បៀងម្ហូបអាហារ ទឹក និងទីជម្រក ព្រមទាំង ថវិការចំនួន១លានដុល្លារបន្ថែមទៀត តាមរយៈអង្គការកម្មវិធីស្បៀងអាហារពិភពលោកដើម្បីជួយដោះស្រាយនូវតម្រូវការម្ហូបអាហារដែលបណ្តាលមកពីការបាត់បង់ផលដំណាំពាសពេញផ្ទៃប្រទេស ។

**ទំនាក់ទំនងសារព័ត៌មានៈ**


លោក **ដេវ ហ្គដថ៍** លេខាធិការទី១ ស្ថានទូតអូស្ត្រាលី រាជធានីភ្នំពេញ

ទូរស័ព្ទលេខៈ ០២៣ ២១៣៤៧០


ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១